# បញ្ចបណ្ឌិតជាតក

## (រឿងបណ្ឌិតទាំង ៤ ដោះស្រាយប្រស្នាអាថ៌កំបាំង)



*បញ្ចបណ្ឌិតជាតកនេះនឹងមានដាក់ច្បាស់ ក្នុងមហាឧមង្គជាតក (សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក មហានិបាត មហោសថជាតក បិដកលេខ ៦២ ទំព័រ ១០២) ។*

***សេចក្ដីខាងក្រោមនេះ ជាអត្ថន័យដែលមានក្នុងព្រះបាលី ៖***

(ព្រះចាងវិទេហៈតាំងបញ្ហាឡើង ត្រាស់ថា)

បញ្ច បណ្ឌិតា សមាគតាត្ថ, បញ្ហា មេ បដិភាតិ តំ សុណាថ;
និន្ទិយមត្ថំ បសំសិយំ វា, កស្សេវាវិករេយ្យ គុយ្ហមត្ថំ។

*អ្នកប្រាជ្ញទាំង ៥ នាក់មកជួបជុំគ្នាហើយ ប្រស្នាក្លឹច្បាស់ដល់យើង អ្នកទាំងឡាយចូរស្តាប់ប្រស្នានោះ អ្នកផងគួរសំដែង ( ប្រាប់) នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំង ដល់នរណា ។*

( អាចារ្យសេនកៈទូលថា )

ត្វំ អាវិករោហិ ភូមិបាល, ភត្តា ភារសហោ តុវំ វទេ តំ;
តវ ឆន្ទរុចីនិ សម្មសិត្វា, អថ វក្ខន្តិ ជនិន្ទ បញ្ច ធីរា។

*បពិត្រព្រះភូមិបាល សូមព្រះអង្គធ្វើឲ្យជាក់ច្បាស់ ដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ព្រះអង្គជាអ្នកចិញ្ចឹម ជាអ្នកអត់ធន់ នូវរាជកិច្ចដ៏ធ្ងន់ សូមព្រះអង្គទ្រង់ពោលប្រស្នានុ៎ះមុន បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំង ៥ នាក់ពិចារណានូវរបស់ជាទីស្រឡាញ់ និងជាទីគាប់ព្រះទ័យ របស់ព្រះអង្គ ហើយនឹងក្រាបទូល ក្នុងកាលជាខាងក្រោយ ។*

( ព្រះចាងវិទេហៈត្រាស់ទ្រាប់គំនិតរបស់ព្រះអង្គថា )

យា សីលវតី អនញ្ញថេយ្យា, ភត្តុច្ឆន្ទវសានុគា ( បិយា ) មនាបា;
និន្ទិយមត្ថំ បសំសិយំ វា, ភរិយាយាវិករេយ្យ គុយ្ហមត្ថំ។

*ភរិយាណា មានសីលពិត ដែលបុរសដទៃលួច ( សម្លឹង ) មិនបាន ជាស្រីប្រព្រឹត្តតាមអំណាចនៃសេចក្តីប្រាថ្នារបស់ភស្តា ជាទីស្រឡាញ់ ជាទីពេញចិត្តនៃភស្តា បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំង ដល់ភរិយា ( នោះ ) ។*

( អាចារ្យសេនកៈទូលព្រះរាជាតាមមតិរបស់ខ្លួនថា )

យោ កិច្ឆគតស្ស អាតុរស្ស, សរណំ ហោតិ គតី បរាយនញ្ច;
និន្ទិយមត្ថំ បសំសិយំ វា, សខិនោ វាវិករេយ្យ គុយ្ហមត្ថំ។

*សម្លាញ់ណាជាទីរលឹក ជាគតិ ជាទីពឹង របស់អ្នកដែលដល់នូវសេចក្ដីលំបាក អ្នកដែលក្ដៅក្រហាយ បុគ្គលគួរប្រាប់នូវសេចក្ដីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់សម្លាញ់ ( នោះ ) ។*

( អាចារ្យបុក្កុសៈទូលថា )

ជេដ្ឋោ អថ មជ្ឈិមោ កនិដ្ឋោ, យោ វេ សីលសមាហិតោ ឋិតត្តោ;
និន្ទិយមត្ថំ បសំសិយំ វា, ភាតុ វាវិករេយ្យ គុយ្ហមត្ថំ។

*បងប្អូនណា ទោះបីជាបងប្អូសក្ដី កណ្ដាលក្ដី ជាប្អូនពៅក្ដី បើបងប្អូននោះតម្កល់នៅស៊ប់ក្នុងសីល មានចិត្តនឹងនួន បុគ្គលគួរប្រាប់នូវសេចក្ដីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំង ដល់បងប្អូន ( នោះ ) ។*

( អាចារ្យកាមិន្ទៈទូលថា )

យោ វេ បិតុហទយស្ស បទ្ធគូ, អនុជាតោ បិតរំ អនោមបញ្ញោ;
និន្ទិយមត្ថំ បសំសិយំ វា, បុត្តស្សាវិករេយ្យ គុយ្ហមត្ថំ។

*កូនប្រុស អ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហឫទ័យរបស់បិតា ជាអ្នកធ្វើតាមពាក្យ ជាអនុជាតបុត្រ មានប្រជ្ញាមិនអន់ថយជាងបិតា បុគ្គលគួរប្រាប់នូវសេចក្ដីដែលគួរនិន្ទាឬគួរសរសើរដែលជា អាថ៌កំបាំង ដល់កូនប្រុស ( នោះ ) ។*

( អាចារ្យទេវិន្ទៈទូលថា )

មាតា ទ្វិបទាជនិន្ទសេដ្ឋ, យា នំ បោសេតិ ឆន្ទសា បិយេន;
និន្ទិយមត្ថំ បសំសិយំ វា, មាតុយាវិករេយ្យ គុយ្ហមត្ថំ។

*បពិត្រព្រះអង្គជាធំជាងជន ដ៏ប្រសើរជាងមនុស្ស មាតាណាចិញ្ចឹមកូននោះ ដោយសេចក្តីស្រឡាញ់ពេញចិត្ត បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំង ដល់មាតា(នោះ)។*

(មហោសធបណ្ឌិតទូលថា)

កុយ្ហស្ស ហិ កុយ្ហមេវ សាធុ, ន ហិ កុយ្ហស្ស បសត្ថមាវិកម្មំ;
អនិប្ផន្នតា សហេយ្យ ធីរោ, និប្ផន្នោវ យថាសុខំ ភណេយ្យ។

*សេចក្តីពិតថា ការលាក់នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់នូវអាថ៌កំបាំង គេមិនសរសើរទេ អ្នកប្រាជ្ញ កាលបើសេចក្តីប្រាថ្នាមិនទាន់សម្រេចនៅឡើយ ត្រូវអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយ តាមសប្បាយចុះ ។*

(នាងឧទុម្ពរាទេវីទូលថា)

កិំ ត្វំ វិមនោសិ រាជសេដ្ឋ, ទ្វិបទជនិន្ទ វចនំ សុណោម មេតំ;
កិំ ចិន្តយមានោ ទុម្មនោសិ, ន្ហន ទេវ អបរាធោ អត្ថិ មយ្ហំ។

*បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គទ្រង់មានព្រះទ័យប្រែប្រួលឬ បពិត្រព្រះអង្គជាធំជាងមនុស្ស ខ្ញុំម្ចាស់ស្តាប់ព្រះតម្រាស់ របស់ព្រះអង្គនោះហើយ តើព្រះអង្គទ្រង់ព្រះចិន្តាដូចម្តេច បានជាទ្រង់តូចព្រះទ័យ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនមានកំហុសទេឬ ។*

(ព្រះចាឡនីទេហៈត្រាស់ថា)

បណ្ហោ វជ្ឈោ មហោសធោ”តិ, អាណត្តោ មេ វធាយ ភូរិបញ្ញោ;
តំ ចិន្តយមានោ ទុម្មនោស្មិ, ន ហិ ទេវី អបរាធោ អត្ថិ តុយ្ហំ។

មហោសធត្រូវគេសម្លាប់ ព្រោះតែប្រស្នាម ហោសធជាអ្នកមានប្រាជ្ញា ដូចផែនដី យើងបង្គាប់គេឲ្យសម្លាប់ហើយ យើងគិតរឿងនោះ បានជាតូចចិត្ត ម្នាលនាងទេវី កំហុសរបស់នាងមិនមានទេឬ ។

(ព្រះចាងវិទេហៈត្រាស់ថា)

អភិទោសគតោ ទានិ ឯហិសិ, កឹ សុត្វា កឹ សង្កតេ មនោ តេ;
កោ តេ កិមវោច ភូរិបញ្ញ, វចនំ សុណោម ព្រូហិ មេតំ។

អ្នកឯង ទើបតែទៅផ្ទះក្នុងពេលព្រលប់សោះ ឥឡូវនេះ ស្រាប់តែមកវិញភ្លាម អ្នកឯងឬដំណឹងដូចម្ដេច ចិត្តរបស់អ្នកឯងរង្កៀសដូចម្ដេច ម្នាលអ្នកមានប្រាជ្ញាដូចផែនដី នរណាបានប្រាប់ដំណឹងដូចម្ដេចដល់អ្នក យើងចង់ស្ដាប់ពាក្យនោះ អ្នកចូរប្រាប់ពាក្យនោះដល់យើង ។

(មហោសធទូលថា)

បណ្ឌោ វធ្ឈោ មហោសធោ”តិ, យទិ តេ មន្តយិតំ ជនិន្ទ ទោសំ;
ភរិយាយ រហោគតោ អសំសិ, គុយ្ហំ បាតុកតំ សុតំ មមេតំ។

បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គស្ដេចទៅក្នុងទីស្ងាត់ បានប្រាប់នូវអាថ៌កំបាំងដែលព្រះអង្គប្រឹក្សាហើយក្នុងពេលព្រលប់ ដល់អគ្គមហេសីថា មហោសធត្រូវគេសម្លាប់ ព្រោះតែប្រស្នា ក្នុងកាលណា សេចក្ដីកំបាំង ឈ្មោះថា ព្រះអង្គធ្វើឲ្យប្រាកដហើយ ក្នុងកាលនោះ សេចក្ដីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។

យំ សាលវនស្មឹ សេនកោ, បាបកម្មំ អកាសិ អសព្ភិរូបំ;
សខិនោវ រហោគតោ អសំសិ, គុយ្ហំ បាតុកតំ សុតំ មមេតំ។

*អាចារ្យសេចកៈបានធ្វើអំពើអាក្រក់ ជាអំពើមានសភាពមិនល្អក្នុងឧទ្យាន ដំដេរដាស ដោយដើមសាលព្រឹក្ស បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់សម្លាញ់ សេចក្តីកំបាំងណាដែល អាចារ្យសេនកៈធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនោះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។*

បុក្កុស បុរិសស្ស តេ ជនិន្ទ, ឧប្បជ្ជោ រោគោ អរាជយុត្តោ;
ភាតុញ្ញ រហោគតោ អសំសិ, គុយ្ហំ ចាតុកាតំ សុតំ មមេតំ។

*បពិត្រព្រះអង្គជាធំជាងជន រោគ (ឃ្លង់) កើតឡើងដល់បុក្កុសបុរស របស់ព្រះអង្គ រោគនោះមិនសមគួរដល់ព្រះរាជាទេ គាត់បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់បងប្អូនប្រុស សេចក្តីកំបាំងណា ដែលអាចារ្យបុក្កុសៈ ធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។*

អាពាធោយំ អសព្ភិរូបោ, កាមិន្ទោ នរទេវេន ផុដ្ឋោ;
បុត្តស្ស រហោគតោ អសំសិ, គុយ្ហំ ចាតុកាតំ សុតំ មមេតំ។

*អាចារ្យកាមិន្ទនេះ មានអាពាធដ៏អាក្រក់ គឺត្រូវនរទេវយក្ខចូល បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់កូនប្រុស សេចក្តីកំបាំងណា ដែលអាចារ្យកាមិន្ទធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។*

អដ្ឋវង្កំ មណិរតនំ ឧឡារំ, សក្កោ តេ អទទា បិតាមហស្ស;
ទេវិន្ទស្ស គតំ តទជ្ជ ហត្ថំ, មាតុញ្ញ រហោគតោ អសំសិ;
គុយ្ហំ ចាតុកាតំ សុតំ មមេតំ។

*ព្រះឥន្ទ្របានថ្វាយមណិរតន៍មានជ្រុង ៨ ដ៏ថ្លៃថ្លា (ដល់ព្រះបាទកុសរាជ) ជាព្រះអយ្យកោរបស់ព្រះអង្គ ថ្ងៃនេះមណិរតន៍នោះទៅនៅក្នុងកណ្តាប់ដៃ នៃអាចារ្យទេវិន្ទហើយ*

*អាចារ្យទេវិន្ទទៅក្នុទីស្ងាត់ ហើយប្រាប់ដល់មាតា សេចក្តីកំបាំងណា ដែលអាចារ្យទេវិន្ទធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ ។*

គុយ្ហស្ស ហិ គុយ្ហមេវ សាធុ, ន ហិ គុយ្ហស្ស បសត្ថមាវិកម្មំ;
អនិប្ផន្នតា សហេយ្យ ធីរោ, និប្ផន្នោវ យថាសុខំ ភណេយ្យ។

*សេចក្តីពិតថា ការលាក់នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់នូវអាថ៌កំបាំង គេមិនសរសើរទេ អ្នកប្រាជ្ញកាលបើសេចក្តីប្រាថ្នាមិនទាន់សម្រេច ត្រូវអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយ តាមសប្បាយចុះ ។*

ន គុយ្ហមត្ថំ វិវរេយ្យ, រក្ខេយ្យ នំ យថា និធឹ;
ន ហិ បាតុកតោ សាធុ, គុយ្ហោ អត្ថោ បជានតា។

*បុគ្គលមិនគប្បីបើកនូវអាថ៌កំបាំង គប្បីរក្សានូវអាថិកំបាំងនោះ ដូចជារក្សានូវកំណប់ ត្បិតថា អាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់ មិនធ្វើឲ្យប្រាកដ ជាការប្រពៃ ។*

ថិយា គុយ្ហំ ន សំសេយ្យ, អមិត្តស្ស ច បណ្ឌិតោ;
យោ ចាមិសេន សំហីរោ, ហទយត្ថេនោ ច យោ នរោ។

*អ្នកប្រាជ្ញមិនគប្បីនិយាយប្រាប់នូវអាថ៌កំបាំងដល់ស្រី ដល់ជនជាសត្រូវ ដល់ជនវៀបវៀប់ដោយអាមិស ដល់ជនលួចគំនិតគ្នា ។*

គុយ្ហមត្ថំ អសម្ពុទ្ធំ, សម្ពោធយតិ យោ នរោ;
មន្តភេទភយា តស្ស, ទាសភូតោ តិតិក្ខតិ។

ជនណាតែងញុាំងអាថ៌កំបាំង ដែលមិនទាន់មានគេដឹងឲ្យគេដឹង អ្នកប្រាជ្ញតែងអត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចជាមនុស្សខ្ញុំគេ ។

យាវន្តោ បុរិសស្សត្ថំ, គុយ្ហំ ជានន្តិ មន្តិនំ;
តាវន្តោ តស្ស ឧព្ពេគា, តស្មា គុយ្ហំ ន វិស្សជេ។

ជនទាំងឡាយប៉ុន្មាននាក់ដឹងនូវមន្តជាអាថ៌កំបាំងរបស់បុរស សេចក្តីតក់ស្លុតប៉ុណ្ណោះតែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញមិនគប្បីផ្សាយ នូវអាថ៌កំបាំង ។

វិវិច្ច ភាសេយ្យ ទិវា រហស្សំ, រត្តឹ គិរំ នាតិវេលំ បមុញ្ចេ;
ឧបស្សុតិកា ហិ សុណន្តិ មន្តំ, តស្មា មន្តោ ខិប្បមុបេតិ ភេទំ។

ក្នុងវេលាថ្ងៃ អ្នកប្រាជ្ញ គប្បីនិយាយអាថ៌កំបាំងក្នុងទីស្ងាត់ មិនគប្បីបញ្ចេញសំឡេងក្នុងវេលាយប់ឲ្យហួសកម្រឹត ព្រោះថា ពួកអ្នកឈ្លបស្តាប់ រមែងឮនូវអាថ៌កំបាំង ដែលប្រឹក្សាគ្នា ព្រោះហេតុនោះ គំនិតដល់នូវការបែកធ្លាយយ៉ាងឆាប់ ។

ចប់ បញ្ចបណ្ឌិតជាតក ៕

( សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក វីសតិនិបាត បិដកលេខ ៦០ ទំព័រ ១៣០)

ថ្ងៃ អាទិត្យ ១០ កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ២២ ខែ កក្កដា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ថ.